# សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ២០១៣ ដោយអគ្គនាយកដ្ឋានពន្ធដារ

នាព្រឹកថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ ២០១៣ ឯកឧត្តម **គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារបានដឹកនាំគណប្រតិភូ របស់អគ្គនាយកដ្ឋានពន្ធដារ ដើម្បីបំពេញដំណើរទស្សនៈកិច្ចនៅអគ្គនាយកដ្ឋានពន្ធដារ របស់ប្រទេសម៉ាឡេស៊ី។

នៅក្នុងដំណើរទស្សនៈកិច្ចគណៈប្រតិភូអគ្គនាយកដ្ឋានពន្ធដារ បានស្វែងយល់និងចែករំលែកបទពិសោធន៍ស្តីពី ៖

- សិក្សាស្វែងយល់ពីប្រព័ន្ធសារពើពន្ធដែលកំពុងអនុវត្តរបស់ប្រទេសម៉ាឡេស៊ី។
- សិក្សាស្វែងយល់ពី Call Center ដែលមានតួនាទីក្នុងការដោះស្រាយបញ្ហាផ្សេងដែលទាក់ទងនិងការបង់ពន្ធ និងផ្តល់ព័ត៌មាន និងរំលឹកដល់អ្នកជាប់ពន្ធដែលមិនទាន់បង់ពន្ធ។
- ការប្រើប្រាស់នូវព័ត៌មានវិទ្យាក្នុងការប្រមូលពន្ធដូចជាតាមរយៈ E-Filling ជាដើម
- ការអប់រំនិងការផ្តល់សេវាដល់អ្នកជាប់ពន្ធ។
- ការគ្រប់គ្រងនូវការបង្វិលសងប្រាក់ពន្ធដែលប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន
- ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានវិទ្យាដែលប្រើប្រាស់សម្រាប់ជួយដល់អ្នកជាប់ពន្ធងាយស្រួលក្នុងការបង់ពន្ធ និងអគ្គនាយកដ្ឋានពន្ធដារក្នុងការគ្រប់គ្រងទិន្នន័យ។



ឯកឧត្តម **គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ លោកTan Sri Dr. Mohd Shukor bin Hj.Mahfar អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារម៉ាឡេស៊ី

នៅក្នុងដំណើរទស្សនៈកិច្ចនេះផងដែរ ឯកឧត្តម **គង់ ទិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ក៏បានជួបសំណេះសំណាលជាមួយ លោក Tan Sri Dr. Mohd Shukor bin Hj.Mahfar អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ របស់ប្រទេសម៉ាឡេស៊ី។ ឯកឧត្តម **គង់ ទិបុល** បានផ្លាស់ប្តូរបទពិសោធន៍ នៃការដឹកនាំនៅអគ្គនាយកដ្ឋានពន្ធដារ ជាពិសេសការកំណែទម្រង់ របស់រាជរដ្ឋាភិបាលកម្ពុជា និងអគ្គនាយកដ្ឋានពន្ធដារ ព្រមពេលជាមួយគ្នានោះផងដែរ លោក Tan Sri Dr. Mohd Shukor bin Hj.Mahfar បានទទួលស្វាគមន៍យ៉ាងកក់ក្តៅចំពោះឯកឧត្តម **គង់ ទិបុល** និងគណៈប្រតិភូ ហើយក៏សម្តែងនូវសេចក្តីសប្បាយរីករាយក្នុងការចែករំលែកបទពិសោធន៍នៃការដឹកនាំនិងគ្រប់គ្រងចំណូលពន្ធដារនៅក្នុងប្រទេសម៉ាឡេស៊ី។ នៅក្នុងឱកាសនោះផងដែរ ឯកឧត្តម **គង់ ទិបុល** ស្នើសុំនូវជំនួយផ្នែកព័ត៌មានវិទ្យាផ្តល់ជូនអគ្គនាយកដ្ឋានពន្ធដារ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រមូលពន្ធនិងផ្តល់សេវាដល់អ្នកជាប់ពន្ធកាន់តែប្រសើរ ។




ឯកឧត្តម **គង់ ទិបុល** និងលោក Tan Sri Dr. Mohd Shukor bin Hj.Mahfar




ឯកឧត្តម **គង់ ទិបុល**ដឹកនាំ គណប្រតិភូរបស់អគ្គនាយកដ្ឋានពន្ធដារនៅប្រទេសម៉ាឡេស៊ី
ថ្ងៃទី ២៥-២៦ ខែវិច្ឆិកា ឆ្នាំ២០១៣